# ច្បាប់ស្តីពី

## ការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១**

ច្បាប់នេះមានគោលដៅបង្ក្រាបអំពើពង្រត់មនុស្សយកទៅលក់ដូរ និងអំពើធ្វើអាជីវកម្ម លើមនុស្ស ដើម្បីធ្វើនីតិសម្បទា និងលើកកំពស់ការគោរពប្រពៃណីជាតិល្អ ការការពារសេចក្តី ថ្លៃថ្នូររបស់មនុស្សនិងការការពារសុខភាពនិងសុខមាលភាពរបស់ប្រជាជន ។

**មាត្រា ២**

ត្រូវហាមឃាត់ដាច់ខាតអំពើពង្រត់មនុស្សយកទៅលក់ដូរ ឬយកទៅធ្វើពេស្យាចារនិងអំពើធ្វើអាជីវកម្មលើមនុស្សនៅក្នុង ឬក្រៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## អំពីអំពើពង្រត់មនុស្សយកទៅលក់ ឬយកទៅធ្វើពេស្យាចារ

**មាត្រា ៣**

ជនណាអូសទាញមនុស្ស ទោះបីស្រីឬប្រុស អនីតិជនឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ វិធីលួងលោមសន្យាឱ្យប្រាក់កាសឬគ្រឿងអលង្ការឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខ ចិត្ត ឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែងឬប្រើថ្នាំសណ្តំស្មារតី និងសតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង ១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ព័ន្ធនាគារពី១៥ ឆ្នាំ ដល់ ២០ឆ្នាំ ។

អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញ ឬទទួលយកត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ ។

ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្តល់ប្រាក់ឬមធ្យោបាយផ្សេងៗសំរាប់ប្រព្រឹត្ត បទល្មើស ។

មធ្យោបាយដឹកជញ្ជូន សម្ភារៈ និងទ្រព្យសម្បត្តិប្រើប្រាស់ ក្នុងពេលប្រព្រឹត្តបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

# ជំពូកទី ៣
# អំពីសព្វារកម្ម

**មាត្រា ៤**

នឹងត្រូវចាត់ទុកជាសញ្ចារិកឬសញ្ចារិកាឬជនមេពេស្យា ជនណា :

១ - ដែលទំនុកបំរុងឬការពារជនណាម្នាក់ឬច្រើននាក់ ទោះបីតាម មធ្យោបាយណាក៏ ដោយ ហើយដោយបានដឹងជាមុននូវអំពើពេស្យាចារ របស់ជននោះឬក៏ទាក់ភ្ញៀវឱ្យជននោះ ក្នុង គោលដៅពេស្យាចារ ឬ

២ -ដែលចែកភាគផល ដែលបានមកពីអំពើពេស្យាចារជាប្រក្រតីទោះជាក្នុងទ្រង់ទ្រាយ ណាក៏ដោយ ឬ

៣ -ដែលយកស្ត្រីឬបុរស ទោះបីតាមមធ្យោបាយណាក៏ដោយទៅបង្ហាត់បង្រៀនបញ្ចុះបញ្ចូលអោយធ្វើជាស្ត្រីឬបុរសជាពេស្យា ឬ

៤ -ដែលធ្វើជាអ្នកកណ្តាល ទោះបីតាមរូបភាពណាក៏ដោយ បង្កើតអោយមានទំនាក់ទំនងរវាងបុរសពេស្យាឬស្ត្រីពេស្យា ជាមួយនិងមេបនពេស្យាចារឬជាមួយអ្នកផ្តល់កម្រៃលើ ពេស្យាចារអ្នកដទៃ ឬ

៥ . ដែលឱ្យបុរសឬស្ត្រី នៅក្នុងផ្ទះរបស់ខ្លួនឬកន្លែងណាមួយ ក្នុងគោលដៅឱ្យជនទាំងនោះធ្វើពេស្យាចារយកប្រាក់ឱ្យខ្លួន ។

**មាត្រា ៥**

សញ្ចារិកឬសញ្ចារិកាឬជនជាមេពេស្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំ ដល់ ១០ ឆ្នាំ ។ ក្នុងករណីមិនរាងចាលត្រូវយកទ្វេរគុណនៃទោសមកអនុវត្ត ។

**ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ក្នុងករណីសព្វារកម្ម :**

១ -ប្រព្រឹត្តបទល្មើសលើអនីតិជនអាយុក្រោម ១៥ឆ្នាំ ឬ

២ -ប្រព្រឹត្តបទល្មើសដោយបង្ខិតបង្ខំវិហិង្សាឬដោយមានការគំរាមកំហែង ឬដោយមាន អាវុធ ឬ

៣ . ប្រព្រឹត្តដោយជា ស្វាមី ភរិយាឬសង្សា ឬឪពុកឬម្តាយឬអាណាព្យាបាល ដែលបង្ខំ បុរស ឬស្ត្រីឱ្យធ្វើពេស្យាចារនៅលើទឹកដីកម្ពុជា ។

តុលាការអាចយកអនុទោសត្រង់ស្ថានបន្ថយសិទ្ធិពលរដ្ឋ និងហាមស្នាក់អាស្រ័យមកផ្តន្ទាបន្ថែមពីលើមូលទោសខាងលើនេះបាន ។

**មាត្រា ៦**

អ្នកសមគំនិតឬអ្នកប៉ុនប៉ងប្រព្រឹត្តបទល្មើសដូច មានចែងក្នុងមាត្រា ៤ និង ៥ត្រូវទទួល ទោសដូចអ្នកប្រព្រឹត្តដែរ ។

# ជំពូកទី ៤
## អំពើអនាចារ

**មាត្រា ៧**

ជនណាដែលបើកកន្លែងសំរាប់ប្រព្រឹត្តអំពើអនាចារឬសំរាប់ប្រព្រឹត្តអំពើអាសអាភាស ផ្សេងៗត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០៛០០ "ប្រាំលានរៀល" ដល់ ៣០.០០០.០០០៛០០ "សាមសិបលានរៀល " ។ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេជាពីរ ។

**មាត្រា ៨**

ជនណាដែលបានប្រព្រឹត្តអំពើអនាចារ លើអនីតិជនអាយុក្រោម ១៥ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក្តី ឬ ដោយទិញក្មេងនោះពីអ្នកដទៃក្តី ឬទិញពីជនជាមេពេស្យាក្តី ជននោះត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ដល់ ២០ឆ្នាំ ។ ក្នុងករណីមិនរាងចាលត្រូវយកអតិបរមានៃ ទោសមកអនុវត្ត ។

តុលាការអាចយកអនុទោសត្រង់ស្ថានបន្ថយសិទ្ធិពលរដ្ឋនិងហាមស្នាក់អាស្រ័យមកផ្តន្ទាទោសបន្ថែមលើមូលទោសខាងលើនេះបាន ។

# ជំពូកទី៥ :
## អវសានប្បញ្ញត្តិ

**មាត្រា៩ :**

ការណែនាំលំអិតសម្រាប់អនុវត្តច្បាប់នេះ ត្រូវកំណត់ដោយអនុក្រិត្យ ។

**មាត្រា១០ :**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៩ខែកុម្ភៈឆ្នាំ១៩៩៦

ក្នុងនាមព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពស់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម